មាត្រា ២០ .- រាល់អនុក្រឹត្យ និងសេចក្តីសម្រេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា២១ .- "គកជ" និងរាល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មការ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

======

# អនុក្រឹត្យ លេខ ៨០ អនក្រ-បក

## ស្តីពីការផ្ទេរអតីតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា និងការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ និងឯកសាររបស់អធិការកិច្ចរាជរដ្ឋាភិបាល អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណូមពរពីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៨

**សំរេច**

មាត្រា ១ .- ត្រូវបានផ្ទេរអតីតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា រួមទាំងធនធានមនុស្ស និងធនធានទ្រព្យ និងក្របខ័ណ្ឌមន្ត្រីរាជការទាំងអស់អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។

មាត្រា ២ .- អតីតរដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ដែលមានចែងក្នុងមាត្រា១ខាងលើ ត្រូវធ្វើជាទីស្តីការក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។

មាត្រា ៣ .- ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ និងឯកសារទាំងអស់របស់អតីតអធិការកិច្ចរាជរដ្ឋាភិបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី អោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច ។

-អតីតអធិការកិច្ចរាជរដ្ឋាភិបាល ត្រូវប្រគល់ការិយាល័យ និងអគារព្រមទាំងបុគ្គលិកការិយាល័យទាំងអស់ អោយមកស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៤ .-** រាល់បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័ន ពាក់ព័ន្ធ និងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ៨១ អនក្រ-បក

## ស្តីពីការផ្ទេរអតីតអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អោយស្ថិតក្រោម ការគ្រប់គ្រងរបស់ក្រសួងធនធានទឹក និង ឧតុនិយម

*****

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមស្មារតីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៨

## សំរេច

**មាត្រា ១ .-** ត្រូវបានផ្ទេរអតីតអគ្គនាយកដ្ឋានធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ និងបណ្តាការិយាល័យធារាសាស្ត្រ ឧតុនិយម និងជលសាស្ត្រ នៅតាមបណ្តាខេត្ត-ក្រុង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រួមទាំងចលនទ្រព្យ និងអចលនទ្រព្យ និងក្របខ័ណ្ឌមន្ត្រីរាជការទាំងអស់អោយស្ថិត នៅក្រោមការគ្រប់គ្រង របស់ក្រសួងធនធានទឹក និងឧតុនិយម ។